# មេរៀនទី ៧៤៖ ពេត្រុសចែកចាយអំពីព្រះយេស៊ូវដោយក្លាហាន

## កិច្ចការ ៤៖៥-១៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/WW48tDY5gpA

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/PysKufW0NMc

**គោលបំណង៖** ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះធ្វើឲ្យយើងរឹងមាំ។

**ខគម្ពីរចងចាំ៖ រ៉ូម១៖១៦** *"ដ្បិតខ្ញុំគ្មានសេចក្ដីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ ពីព្រោះជាព្រះចេស្ដានៃព្រះ សំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ គឺដល់ទាំងសាសន៍យូដាជាដើម និងសាសន៍ក្រេកផង។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ពេត្រុសអើយ https://youtu.be/ASM21vLgdf4
២. ព្រះនឹងរៀបចំផ្លូវ https://youtu.be/pKmid-FNhhw
៣. បេសកកម្មដំណឹងល្អ https://youtu.be/T1WMFhM4Sxk

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «ឈោងចាប់ មនុស្ស»**



១.ជ្រើសរើសកុមារម្នាក់ធ្វើជា "អ្នកចាំទី" ហើយអ្នកចាំ ទី ត្រូវឈរនៅជ្រុងម្ខាងនៃថ្នាក់រៀន។
២.កុមារផ្សេងទៀតត្រូវឈរនៅជ្រុងម្ខាងទៀត នៃថ្នាក់រៀន។
៣.នៅពេលដែលគ្រូចាប់ផ្ដើមរាប់១ ២ ៣ "អ្នកចាំទី" ត្រូវ ចាប់ផ្ដើមរត់ជុំវិញថ្នាក់រៀនដើម្បីដេញចាប់កុមារផ្សេង ទៀត។
៤. នៅពេលដែលកុមារដែលជា "អ្នកចាំទី" ចាប់បានកុមារណាម្នាក់ កុមារនោះត្រូវក្លាយជាសមាជិករបស់ អ្នកចាំទី ហើយគេត្រូវជួយអ្នកចាំទី ដេញចាប់កុមារផ្សេងទៀត។
៥. បន្តលេងល្បែងនេះរហូតដល់ចាប់បានកុមារទាំងអស់។
៦.សូមពន្យល់ដល់កុមារថា យើងអាចធ្វើការជាមួយគ្នា ក្នុងការចែកចាយដំណឹងល្អ ដើម្បីសង្គ្រោះមិត្តភក្តិរបស់យើង។

**៤. ការណែនាំមេរៀន**

បន្ទាប់ពីព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញ ទ្រង់បានសន្យាថា ព្រះអង្គនឹងបញ្ជូនអ្នកជំនួយជួយដល់អស់អ្នក ដែលជឿដល់ព្រះនាមទ្រង់។ ព្រះយេស៊ូវបានរក្សាការសន្យារបស់ទ្រង់ ដោយបានបញ្ជូនព្រះវិញ្ញាណបរិសុទ្ធឲ្យមក។ នៅពេលដែលយើងដាក់សេចក្ដីជំនឿរបស់យើងលើព្រះជាម្ចាស់ ព្រះវិញ្ញាណ

បរិសុទ្ធនឹងមកគង់នៅក្នុងចិត្តរបស់យើង ផ្តល់ឲ្យយើងនូវកម្លាំង ជំនឿ ការលើកទឹកចិត្ត ហើយនឹងដឹកនាំយើង។ ព្រះវិញ្ញាណបរិសុទ្ធគឺគង់នៅជាមួយគ្រិស្តបរិស័ទគ្រប់ៗគ្នា។ ព្រះវិញ្ញាណបរិសុទ្ធបានជួយធ្វើឲ្យយើងរឹងមាំក្នុងការចែកចាយអំពីព្រះយេស៊ូវ។ ហើយនេះគឺជារឿងរ៉ាវ ដែលកើតមានឡើងយ៉ាងពិតប្រាដក ចំពោះបុគ្គលពីរនាក់នៅក្នុងព្រះគម្ពីរ ដែលពួកយើងនឹងសិក្សាជាមួយគ្នានៅថ្ងៃនេះ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយពេត្រុស និងយូហានបានទៅឯព្រះវិហារ។ បុរសពិការពីកំណើតម្នាក់ត្រូវបានគេដឹកទៅដាក់នៅក្លោងទ្វារព្រះវិហារ។ ពេត្រុសបានប្រោសបុរសម្នាក់នោះឲ្យជាក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ហើយប្រាប់បុរសនោះឲ្យក្រោកដើរ។ នៅពេលដែលពួកសង្ឃ និងពួកសាឌូស៊ី បានឮពីការចែកចាយរបស់ពេត្រុស និងយ៉ូហាន អំពីការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវ ហើយបានប្រោសមនុស្សឲ្យជា ពួកគេខឹងខ្លាំងណាស់។ ពួកគេមិនដឹងថា ពួកគេត្រូវធ្វើអ្វីនោះទេ ដូច្នេះពួកគេបានចាប់ពេត្រុស និងយូហានដាក់គុក។

នៅថ្ងៃបន្ទាប់ ពេត្រុស និងយ៉ូហានត្រូវបានគេនាំទៅចំពោះមុខពួកសង្ឃ និងពួកអ្នកបង្កើតច្បាប់។ ពួកគេក៏ចាប់ផ្តើមសួរ ពេត្រុស និងយ៉ូហានថា "ឯងបានធ្វើការនោះដោយអាងអំណាចអ្វី ឬដោយអាងឈ្មោះណា?" ពេត្រុសមិនខ្លាចក្នុងការឆ្លើយតបនោះទេ។ នៅពេលនោះពេត្រុសបានពេញដោយ ព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណបរិសុទ្ធបានពង្រឹងសេចក្តីជំនឿរបស់ពេត្រុស ហើយបានប្រទានឲ្យ គាត់នូវភាពក្លាហានក្នុងការនិយាយជាមួយពួកអ្នកដែលបានចាប់គាត់ដាក់គុកនោះ។

ពេត្រុសបានប្រាប់ពួកគេថា "គឺដោយសារព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត ដែលលោករាល់គ្នាបានឆ្កាងទ្រង់ តែព្រះបានប្រោសឲ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ។" អ្នកបង្កើតច្បាប់ក៏មានការភ្ញាក់ផ្អើល។ ពេត្រុស និងយ៉ូហានគ្រាន់តែជាមនុស្សធម្មតាតែប៉ុណ្ណោះ។ ពួកគេគឺជាអ្នកនេសាទត្រី។ ពួកគេមិនមានចំណេះដឹងជ្រៅជ្រះ ឬក៏សិទ្ធអំណាចអីនោះទេ។ តើពួកគេអាចនិយាយនឹងធ្វើរឿង ដ៏អស្ចារ្យទាំងនេះដោយរបៀបណា? ពួកអ្នកបង្កើតច្បាប់បានដឹងថា ពេត្រុស និងយ៉ូហាន មានចិត្តក្លាហាន និងមានអំណាចគ្រប់ពាក្យពេចន៍ដែលគេបាននិយាយ។ ពួកអ្នកបង្កើតច្បាប់មិនដឹងថា ពួកគេត្រូវធ្វើអ្វីនោះទេ។ ទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ ក៏ពេត្រុស និងយ៉ូហានបានដឹងថាពួកគេមានព្រះវិញ្ញាណរបស់ព្រះ ដើម្បីផ្តល់កម្លាំងដល់ពួកគេដែរ។

នៅពេលដែលយើងជឿលើព្រះយេស៊ូវ ហើយដាក់សេចក្តីជំនឿរបស់យើងលើទ្រង់ នោះយើងបានក្លាយជាគ្រីស្ទបរិស័ទ។ នៅពេលដែលយើងមានសេចក្តីជំនឿលើព្រះជាម្ចាស់ទ្រង់នឹងអត់ទោសឲ្យ ហើយសង្គ្រោះយើងពីអំពើបាបរបស់យើង។ បន្ទាប់មកយើងនឹងដើរតាមផ្លូវរបស់ព្រះ - ផ្លូវនៃសេចក្តីសប្បុរស ផ្លូវនៃពន្លឺ និងផ្លូវនៃសេចក្តីស្រឡាញ់។ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងជួយយើងឲ្យធ្វើដូច្នោះ។ ទ្រង់ប្រទានកម្លាំងឲ្យដល់យើងដើម្បីមានចិត្តសប្បុរស និងសេចក្តីស្រឡាញ់ ហើយរស់នៅក្នុងពន្លឺ។

យើងទាំងអស់គ្នាត្រូវការព្រះនៅក្នុងជីវិតរស់នៅរបស់យើង។ មានរឿងលំបាកជាច្រើន ដែលកើតមានឡើងក្នុងជីវិតរស់នៅលើផែនដីនេះ។ យើងអាចប្រឈមមុខនឹងគ្រាដ៏លំបាកបានដោយងាយ នៅពេលដែលយើងមានព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយ។ ប៉ុន្តែមានមនុស្សជាច្រើនដែលមិនជឿលើព្រះ ពួកគេត្រូវប្រឈមជាមួយពេលវេលាដ៏លំបាកនោះដោយខ្លួនឯង។ ហើយនេះជាហេតុផលមួយដ៏សំខាន់ក្នុងការប្រាប់អ្នកដទៃ អំពីព្រះយេស៊ូវ យើងចង់ឲ្យមនុស្សគ្រប់គ្នាទទួលជឿព្រះ ហើយឲ្យមានព្រះវិញ្ញាណបរិសុទ្ធ

គង់នៅក្នុងជីវិតរបស់ពួកគេ។ សូមឲ្យយើងបានធ្វើដូចជា ពេត្រុស ហើយនិយាយជាមួយអ្នកដទៃ អំពីព្រះយេស៊ូវដោយចិត្តក្លាហាន!

### ៦. សំនួរពិភាក្សា

១. តើសាវកដែលត្រូវគេចាប់ដាក់គុកមានឈ្មោះអ្វីខ្លះ? *(ពេត្រុស និងយ៉ូហាន)*

២.ហេតុអ្វីបានពួកគេចាប់គាត់ដាក់គុក? *(ពួកគាត់បានប្រោសបុរសម្នាក់ឲ្យជានៅក្នុងព្រះនាមព្រះយេស៊ូ)*

៣.ហេតុអ្វីបានជាពេត្រុសមិនមានភាពភ័យខ្លាចក្នុងការចែកចាយអំពីព្រះយេស៊ូវ? *(ពីព្រោះថាគាត់បានពេញ ដោយព្រះវិញ្ញាណបរិសុទ្ធ)*

៤.តើនរណាខ្លះដែលអាចទទួលបានព្រះវិញ្ញាណបរិសុទ្ធ? *(គ្រិស្តបរិស័ទទាំងអស់ ដែលជឿលើព្រះយេស៊ូវ)*

៥.តើព្រះវិញ្ញាណបរិសុទ្ធធ្វើអ្វីសម្រាប់អ្នក? *(ជួយឲ្យអ្នកមានចិត្តសប្បុរស សេចក្តីស្រឡាញ់ និងភាពក្លាហាន)*

### ៧. ល្បែងកំសាន្ត «បំបែកប៉េងប៉ោង»

សម្ភារៈដែលត្រូវការ៖ ប៉េងប៉ោង និងកៅអី





១.ចែកកុមារជា ៣ក្រុមស្មើៗគ្នា ហើយឲ្យប៉េងប៉ោងទៅកុមារគ្រប់ៗគ្នា។

២. ដាក់កៅអីនៅជ្រុងទាំង បី ឃ្លាតៗពីគ្នា។

៣. នៅពេលដែលគ្រូស្រែកថា ១ ២ ៣ ចាប់ផ្តើម ពេលនោះ កុមារគ្រប់គ្នាត្រូវចាប់ផ្តើមផ្លុំ ប៉េងប៉ោងរបស់ពួកគេ (រួចចងមាត់) ហើយរត់ទៅកាន់កៅអី។ នៅពេលដែលកុមាររត់ទៅដល់កៅអីហើយ គេត្រូវដាក់ប៉េងប៉ោងនៅលើកៅអី ហើយបំបែកវាដោយអង្គុយពីលើ។ បន្ទាប់មកគេត្រូវរត់ទៅកាន់ក្រុមរបស់ពួកគេវិញ។

៤. ក្រុមណាដែលអាចបំបែកប៉េងប៉ោងបានអស់មុនគេក្រុមនោះគឺជាអ្នកឈ្នះ។

៥.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពេលខ្លះការផ្លុំប៉េងប៉ោងគឺពិបាក ឬក៏ការបំបែកប៉េងប៉ោងពិបាក។ ទាំងនេះគឺជាឧបសគ្គមួយចំនួន ដែលនឹងរារាំងយើងពីការសម្រេចគោលដៅរបស់យើង ប៉ុន្តែយើងទាំងអស់គ្នានៅតែអាចបញ្ចប់ការប្រកួតនេះបាន។ ដូចគ្នានេះដែរ ដោយកម្លាំងដែលយើងទទួលបានពីព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចបញ្ចប់ការប្រកួត ដោយការចែកចាយដំណឹងល្អ។

### ៨. ខគម្ពីរចងចាំ

**រ៉ូម១៖១៦** *"ដ្បិតខ្ញុំគ្មានសេចក្ដីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ ពីព្រោះជាព្រះចេស្ដា នៃព្រះសំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ គឺដល់ទាំងសាសន៍យូដាជាដើម និងសាសន៍ ក្រេកផង។"*

### ៩. ហាត្ថកម្ម

សូមផាត់ពណ៌ទំព័រ ពេត្រុសចែកចាយអំពីព្រះយេស៊ូវដោយក្លាហាន។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ពេលជួបទុក្ខលំបាក តើអ្នកងាកទៅរកភាពក្លាហាន និងកម្លាំងពីណា? ពិភពលោកបង្រៀនយើងថា យើងគួរជឿជាក់លើខ្លួនឯង។ កុំធ្លាក់ក្នុងការកុហកនេះ។ បើគ្មានព្រះទេ គ្មានអ្វីដែលយើងអាចធ្វើបាន ដើម្បីសង្គ្រោះខ្លួនយើងពីបញ្ហាលោកីយ៍នេះទេ។ រំលឹកខ្លួនអ្នកជារៀងរាល់ថ្ងៃថា "ខ្ញុំដឹងថា ព្រះជាម្ចាស់អាចធ្វើបាន។ ខ្ញុំដឹងថាព្រះអាច ខ្ញុំដឹងថាព្រះអាចធ្វើបាន!" ចូរទុកចិត្តលើព្រះដែលបានផ្តល់ សេចក្តីក្លាហានដល់អ័ប្រាហាំ នាងរស់ ម៉ូសេ រ៉ាហាប ដាវីឌ អេសធើរ ដានីយ៉ែល ម៉ារៀ និងពេត្រុស… ហើយព្រះនឹងប្រទានឲ្យអ្នកនូវភាពក្លាហានដើម្បីយកឈ្នះលើពិភពលោកនេះ!

# Peter Speaks About Jesus Courageously



សូមសរសេរខគម្ពីរចងចាំ: